# ចម្រៀងចាប៉ី

កំលោះទី១៖ អើយ ... លើកហត្ថឡើងប្រណម្យ បង្គំចំពោះញាតិប្រុសស្រី ស្ដាប់ចម្រៀងខ្ញុំច្រៀងចាប៉ី
បើមានទាស់អ្វីសូមប្រណីផង ដើណានាងណា បើមានទាស់អ្វីសូមប្រណីផង។

អើយ ... ព្រោះខ្ញុំនៅកំលោះ ស្រណោះផងចុះបើខុសឆ្គង ទើបនឹងជួបអស់លោកម្ដង
បំណងច្រៀងជូនបងប្អូនកំសាន្ត ដើណានាងណា បំណងច្រៀងជូនបងប្អូនកំសាន្ត។

អើយ ... ខ្ញុំជាសុភាពបុរស មិនចូលចិត្តសោះស្រាកញ្ឆាសាមាន្យ អាណិតខ្ញុំសុំរាប់អាន
ប្រុសស្រីគ្រប់ប្រាណកុំប្រកាន់អី ដើណានាងណា ប្រុសស្រីគ្រប់ប្រាណកុំប្រកាន់អី។

អើយ ... តទៅខ្ញុំសូមច្រៀងចម្រៀងរៀបរាប់ពីស្រីៗ មាននាងខ្លះនឹកចង់បានប្ដី
ជាន់ចានជាន់ល្អីទាល់តែបាក់បែក ដើណានាងណា ជាន់ចានជាន់ល្អីទាល់តែបាក់បែក។

អើយ ... នាងខ្លះចង់បានប្ដីក្មេង បើប៉ះដៃក្រវែងកុំឱ្យតែដងវែក បើច្រមុះក្រពិតសុំឱ្យតែជាភ្នែក
ស្រីខ្លះចង់ប្លែកចង់បានគ្រូសូត្រ ដើណានាងណា ស្រីខ្លះចង់ប្លែកចង់បានគ្រូសូត្រ។

អើយ ... ខ្លះចង់បានប្ដីហ៊ឺហា បើសិនផឹកស្រាឱ្យតែផឹកស្លូត បើចេះភរកុំឱ្យតែលាយភូត
បើទុកជាមុខខ្ទួតកុំឱ្យតែកើតស្រែង ដើណានាងណា បើទុកជាមុខខ្ទួតកុំឱ្យតែកើតស្រែង។

អើយ ... លោកអ្នកគិតមើលចុះ ស្រីៗទាំងអស់គិតខុសមិនបាច់ថ្លែង បើមិនស្រឡាញ់ខ្ញុំ ខ្ញុំនៅម្នាក់ឯង
ស្វែងរកគូព្រេង ព្រេងឯណាទៀត ដើណានាងណា ស្វែងរកគូព្រេង ព្រេងឯណាទៀត។

កំលោះទី២៖ ឈប់! ឈប់សិន!
អើយ ... អស់លោកកុំជឿអី មនុស្សនេះចង្រៃចិត្តចោលម្សៀត មានប្រពន្ធហើយចង់បានប្រពន្ធទៀត
មារយាទបែបហ្នឹងដេញចេញទៅ!

កំលោះទី១៖ ដើណានាងណា ថាអញមិនទៅ! ថាអញមិនទៅ!

កំលោះទី១៖ អើយ ... តើឯងមកពីណា មើលអញដូចជាខ្មាំងសត្រូវ

កំលោះទី២៖ នែ៎ សុំប្រាប់ឱ្យហើយទៅ ប្រពន្ធហៅឱ្យទៅផ្ទះ ដើណានាងណា ប្រពន្ធហៅឱ្យទៅផ្ទះ។

កំលោះទី២៖ អើយ ... អស់លោកសុំកុំជឿ ...

កំលោះទី១៖ នែ៎ អាកន្ទ្បើកុំថាតែផ្ដាស់!

កំលោះទី២៖ នែ៎ លោកបងកុំមុខក្រាស់ មានប្រពន្ធនៅផ្ទះកុំថាកំលោះអី ដើណានាងណា
មានប្រពន្ធនៅផ្ទះកុំថាកំលោះអី។

សិល្បករ៖ សិន ស៊ីសាមុត និង មាស សាម៉ន?

